# AIA សម្រាប់សុខភាព សំណួរដែលត្រូវបានសួរញឹកញាប់ (FAQs)

VERSION 2.0 LAST UPDATE: 20TH JUNE 2023 BY: PRODUCT DEVELOPMENT TEAM

## មាតិកា


I. ព័ត៌មានអំពីផលិតផល....4

1. តើអ្វីទៅជា AIA សម្រាប់សុខភាព?.... 4
2. តើអ្នកណាខ្លះអាចទិញ AIA សម្រាប់សុខភាព បាន?.... 4
3. តើរយៈពេលនៃការធានារ៉ាប់រងរបស់ផលិតផលនេះមានរយៈពេលប៉ុន្មាន?.... 4
4. តើអ្វីទៅជាកម្រិតអតិបរមាក្នុងមួយជីវិត?.... 4
5. តើចំនួនទឹកប្រាក់ធានារ៉ាប់រងអប្បបរមាសម្រាប់អត្ថប្រយោជន៍លើមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍គឺប៉ុន្មាន?.... 4
6. តើខ្ញុំអាចទិញផលិតផល AIA សម្រាប់សុខភាព ដោយភ្ជាប់វាទៅនឹងគម្រោងធានារ៉ាប់រងដែលខ្ញុំមានស្រាប់ដែរឬទេ?.... 4
7. តើខ្ញុំមានប៉ុន្មានជម្រើសដើម្បីបង់បុព្វលាភធានារ៉ាប់រងរបស់ខ្ញុំ?.... 5
8. តើអ្វីទៅជា "រយៈពេលនៃការរងចាំ"? តើវាប្រព្រឹត្តទៅយ៉ាងដូចម្តេច?.... 5
9. តើអ្វីទៅជារយៈពេលពិចារណាចុងក្រោយ?.... 5
10. តើអ្វីទៅជារយៈពេលអនុគ្រោះ?.... 5

II. ទីតាំងភូមិសាស្ត្រនៃការធានា....6

11. តើអ្វីទៅជាទីតាំងភូមិសាស្ត្រនៃការធានា?.... 6
12. ហេតុអ្វីបានជាផលិតផលនេះមិនការពារនៅសហរដ្ឋអាមេរិក?.... 6
13. តើផលិតផលនេះការពារលើការសង្គ្រោះបន្ទាន់ទូទាំងពិភពលោកដែរឬទេ?.... 6

III. គម្រោងគ្រួសារ....6

14. ប្រសិនបើខ្ញុំទិញផលិតផល AIA សម្រាប់សុខភាព សម្រាប់សមាជិកគ្រួសាររបស់ខ្ញុំ តើពួកយើងអាចស្ថិតក្រោមបណ្ណសន្យារ៉ាប់រងតែមួយដែរឬទេ?.... 6
15. សម្រាប់គម្រោងគ្រួសារ តើសមាជិកអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗទទួលបានកាតធានារ៉ាប់រងផ្ទាល់ខ្លួនដែរឬទេ?.... 6
16. សម្រាប់គម្រោងគ្រួសារ ប្រសិនបើមានសមាជិក 5 នាក់ក្នុងបណ្ណសន្យារ៉ាប់រងតែមួយ ហើយសមាជិកខ្លះបានប្រើប្រាស់អស់កម្រិតអតិបរមាសរុបសម្រាប់មួយជីវិត តើក្នុងករណីនេះនឹងមានអ្វីកើតឡើងចំពោះបណ្ណសន្យារ៉ាប់រងទាំងមូល?.... 7
17. តើនឹងមានអ្វីកើតឡើងចំពោះគម្រោងគ្រួសារ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងគោលបានទទួលមរណភាព ឬទាមទារសំណងលើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍?.... 7

IV. ការចូលរួមចំណែកនៃការចំណាយ....7


FOR INTERNAL USE ONLY

18. តើអ្វីទៅជាការចូលរួមចំណែកនៃការចំណាយ? ..... 7
19. តើអ្វីទៅជាកម្រិតអតិបរមាសម្រាប់ចំណាយពីហោប៉ៅផ្ទាល់ខ្លួន? ..... 7
20. តើមានជម្រើសអោយខ្ញុំជ្រើសរើសភាគរយសម្រាប់គម្រោងការចូលរួមចំណែកនៃការចំណាយដែរឬទេ? ..... 8
21. ហេតុអ្វីបានជាអតិថិជនត្រូវបង់ការចូលរួមចំណែកនៃការចំណាយ10%? ..... 8
22. តើអតិថិជនបង់ការចូលរួមចំណែកនៃការចំណាយនៅពេលណា? ..... 8
23. តើអត្ថប្រយោជន៍លើមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍មានការចូលរួមចំណែកនៃការចំណាយដែរឬទេ? . 8

V. កម្រិតមិនធ្វើសំណង ..... 9

24. តើអ្វីទៅជាកម្រិតមិនធ្វើសំណង? ..... 9
25. តើអ្នកណាខ្លះគួរទិញគម្រោងកម្រិតមិនធ្វើសំណង? ..... 9

VI. ការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណង & កាបូបលុយសម្រាប់ការថែទាំសុខភាព ..... 10

26. តើអ្វីទៅជាអត្ថប្រយោជន៍លើកទឹកចិត្តសម្រាប់ការមិនទាមទារសំណង? ..... 10
27. តើខ្ញុំអាចប្រើប្រាស់អត្ថប្រយោជន៍លើកទឹកចិត្តសម្រាប់ការមិនទាមទារសំណងបានយ៉ាងដូចម្តេច? ..... 10
28. តើខ្ញុំអាចដកប្រាក់នៅក្នុងកាបូបលុយសម្រាប់ការថែទាំសុខភាពបានដែរឬ? ..... 10
29. តើខ្ញុំត្រូវបង់ការចូលរួមចំណែកនៃការចំណាយ 10% សម្រាប់អត្ថប្រយោជន៍ការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណងដែរឬទេ? ..... 11
30. នៅក្រោមកញ្ចប់គ្រួសារ តើអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗមានកាបូបលុយសម្រាប់ការថែទាំសុខភាពរៀងៗខ្លួនដែរឬទេ? ..11
31. នៅក្រោមកញ្ចប់គ្រួសារ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងគោលបានធ្វើការទាមទារសំណងលើអត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ តើវានឹងប៉ះពាល់ដល់កាបូបសម្រាប់ការថែទាំសុខភាពរបស់សមាជិកគ្រួសារផ្សេងទៀតដែរឬទេ? ..... 11

VII. បុព្វលាភធានារ៉ាប់រង ..... 11

32. តើបុព្វលាភធានារ៉ាប់រងរបស់ផលិតផលនេះថេរក្នុងកំឡុងពេលនៃការធានារ៉ាប់រងដែរឬទេ? ..... 11
33. តើអ្វីទៅធ្វើឱ្យបុព្វលាភធានារ៉ាប់រងនៃគម្រោងវេជ្ជសាស្ត្រកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ? ..... 12
34. ហេតុអ្វីបានជាបុព្វលាភធានារ៉ាប់រងនៃគម្រោងវេជ្ជសាស្ត្រមិនត្រូវបានធានា? ..... 12
35. តើការបន្តសុពលភាពប្រចាំឆ្នាំសម្រាប់ផលិតផលនេះត្រូវបានធានាដែរឬទេ? ..... 12
36. ប្រសិនបើខ្ញុំទាមទារសំណងច្រើនក្នុងមួយឆ្នាំនៃបណ្ណសន្យារ៉ាប់រង តើក្រុមហ៊ុន AIA នឹងឈប់បន្តបណ្ណសន្យារ៉ាប់រងរបស់ខ្ញុំ ឬដំឡើងបុព្វលាភធានារ៉ាប់រងរបស់ខ្ញុំឱ្យច្រើនឡើងនៅឆ្នាំបន្ទាប់ដែរឬទេ? ..... 12

VIII. ការផ្លាស់ប្តូរបណ្ណសន្យារ៉ាប់រង ..... 13

37. តើអតិថិជនអាចបំប្លែងគម្រោងវេជ្ជសាស្ត្រដែលមានស្រាប់របស់ពួកគេទៅជាគម្រោងមួយផ្សេងទៀតដែរឬទេ? ..... 13
38. តើរយៈពេលនៃការរងចាំត្រូវបានអនុវត្តយ៉ាងដូចម្តេចបន្ទាប់ពីការបំប្លែងគម្រោង? ..... 13
39. ប្រសិនបើខ្ញុំបានស្នើសុំដំឡើងគម្រោង ហើយត្រូវបានច្រានចោល តើខ្ញុំនៅតែអាចបន្តជាមួយគម្រោងដែលមានស្រាប់របស់ខ្ញុំបានដែរឬទេ? ..... 13
40. តើកម្រិតអតិបរមាក្នុងមួយជីវិតនឹងបង្ហាញយ៉ាងដូចម្តេចសម្រាប់មួយរយៈពេលនៃការធានារ៉ាប់រង? ..... 14
41. តើកម្រិតអតិបរមាក្នុងមួយជីវិតនឹងទៅជាយ៉ាងណាបន្ទាប់ពីការបំប្លែងគម្រោង? ..... 15
42. តើខ្ញុំអាចផ្លាស់ប្តូររបៀបបង់បុព្វលាភធានារ៉ាប់រងបានទេ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងនេះចូលជាធរមាន? ..... 15


FOR INTERNAL USE ONLY

IX. ការទាមទារសំណង........ 15

43. តើខ្ញុំដាក់ពាក្យទាមទារសំណងបានដោយរបៀបណា?........ 15
44. តើឯកសារអ្វីខ្លះដែលខ្ញុំត្រូវមានសម្រាប់ការទាមទារសំណងប្រាក់ត្រលប់មកវិញ?........ 15
45. តើឯកសារអ្វីខ្លះដែលខ្ញុំត្រូវមានដើម្បីប្រើប្រាស់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់នៅមន្ទីរពេទ្យដៃគូរក្នុងស្រុករបស់ក្រុមហ៊ុន AIA?........ 16
46. តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីប្រើប្រាស់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់នៅមន្ទីរពេទ្យដៃគូរក្រៅស្រុករបស់ក្រុមហ៊ុន AIA? 16
47. តើខ្ញុំអាចទទួលបានទម្រង់បែបបទការស្នើសុំការអនុញ្ញាតជាមុននៅឯណា?........ 16
48. ខ្ញុំមានគម្រោងទៅព្យាបាលនៅមន្ទីរពេទ្យដែលមិនមែនជាមន្ទីរពេទ្យដៃគូរបស់ក្រុមហ៊ុន AIA តើខ្ញុំអាចទាមទារសំណងលើថ្លៃព្យាបាលបានដែរឬទេ?........ 16
49. តើក្រុមហ៊ុន AIA ប្រើពេលប៉ុន្មានថ្ងៃដើម្បីដំណើរការការទាមទារសំណង?........ 17
50. តើអ្វីទៅជាការស្នើសុំការអនុញ្ញាតជាមុន?........ 17
51. តើខ្ញុំអាចជូនដំណឹងទៅក្រុមហ៊ុន AIA អំពីការស្នើសុំការអនុញ្ញាតជាមុនដោយវិធីណា?........ 17
52. តើនឹងមានការផាកពិន័យ ឬការបដិសេធនៃការទាមទារសំណងដែរឬទេ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមិនបានស្នើសុំការអនុញ្ញាតជាមុន?........ 17
53. តើមន្ទីរពេទ្យណាខ្លះដែលខ្ញុំអាចប្រើប្រាស់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់សម្រាប់ការព្យាបាលបាន?........ 18
54. តើខ្ញុំអាចទាមទារសំណងលើថ្លៃព្យាបាលសម្រាប់ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងទាមទារសំណងលើអត្ថប្រយោជន៍ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ បានដែរឬទេ?........ 18
55. តើមន្ទីរពេទ្យនឹងជូនដំណឹងដល់អតិថិជនអំពីអត្ថប្រយោជន៍ដែលពួកគេត្រូវបានធានារ៉ាប់រង និងចំនួនទឹកប្រាក់ដែលពួកគេត្រូវចំណាយពីហោប៉ៅផ្ទាល់ខ្លួនបានដែរឬទេ?........ 18
56. តើខ្ញុំអាចទូទាត់ប្រាក់ត្រលប់មកវិញបានដែរឬទេក្នុងរយៈពេលអនុគ្រោះ?........ 18
57. តើខ្ញុំអាចទូទាត់ប្រាក់ត្រលប់មកវិញបានដែរឬទេក្នុងកំឡុងពេលដែលបណ្ណសន្យារ៉ាប់រងអស់សុពលភាព?........ 18
58. តើខ្ញុំអាចតាមដានស្ថានភាពនៃការទាមទារសំណងដែលខ្ញុំបានដាក់ស្នើដោយរបៀបណា?........ 18

X. ការបញ្ចប់បណ្ណសន្យារ៉ាប់រង........ 19

59. បន្ទាប់ពីបណ្ណសន្យារ៉ាប់រងត្រូវបានបញ្ចប់ តើខ្ញុំអាចទិញបណ្ណសន្យារ៉ាប់រងថ្មីបានដែរឬទេ?........ 19
60. តើខ្ញុំអាចដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញបានដែរឬទេ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងរបស់ខ្ញុំអស់សុពលភាព?19

XI. ប្រតិបត្តិការបណ្ណសន្យារ៉ាប់រង........ 19

61. តើត្រូវចំណាយពេលប៉ុន្មានថ្ងៃដើម្បីចេញកាតធានារ៉ាប់រង?........ 19
62. តើក្រុមហ៊ុននឹងផ្តល់ជូនកាតធានារ៉ាប់រងជារៀងរាល់ឆ្នាំដែរឬទេ ព្រោះផលិតផលនេះមាន រយៈពេលធានារ៉ាប់រង 100 ឆ្នាំ?20
63. តើខ្ញុំអាចទទួលបានព័ត៌មានលម្អិតអំពីការធានារ៉ាប់រងរបស់ខ្ញុំដោយរបៀបណា?........ 20
64. តើផលិតផលនេះរាប់បញ្ចូលទៅក្នុងភាពទៀងទាត់នៃការបង់បុព្វលាភ (persistency) របស់ទីប្រឹក្សាផែនការជីវិតដែរឬទេ? 20
65. តើមនុស្សម្នាក់អាចការពារក្រោមបណ្ណសន្យារ៉ាប់រងតែមួយប៉ុណ្ណោះមែនដែរឬទេ?........ 20

FOR INTERNAL USE ONLY

# I. ព័ត៌មានអំពីផលិតផល

## 1. តើអ្វីទៅជា AIA សម្រាប់សុខភាព?

ការធានារ៉ាប់រងបន្ថែមផ្នែកវេជ្ជសាស្ត្រសម្រាប់បុគ្គលម្នាក់ៗយ៉ាងទូលំទូលាយដែលទូទាត់លើចំណាយថ្លៃព្យាបាល (ឧ. បន្ទប់ និងគ្រែប្រចាំថ្ងៃ ការវះកាត់ ថ្លៃសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។ល។) ដែលកើតឡើងដោយអ្នកត្រូវបានធានារ៉ាប់រងដែលបណ្តាលពីជំងឺ ឬរបួសពីគ្រោះថ្នាក់ចៃដន្យណាមួយ។ អ្នកត្រូវបានណែនាំឱ្យអានកិច្ចសន្យារ៉ាប់រងសម្រាប់ព័ត៌មានលំអិតអំពីអត្ថប្រយោជន៍ និងករណីមិនធានា។

## 2. តើអ្នកណាខ្លះអាចទិញ AIA សម្រាប់សុខភាព បាន?

អ្នកដែលមានអាយុចន្លោះពី 30 ថ្ងៃ ដល់ 69 ឆ្នាំ មានសិទ្ធិទិញ AIA **សម្រាប់សុខភាព**។

## 3. តើរយៈពេលនៃការធានារ៉ាប់រងរបស់ផលិតផលនេះមានរយៈពេលប៉ុន្មាន?

ផលិតផល AIA **សម្រាប់សុខភាព** គឺជាផលិតផលធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រពេញមួយជីវិតសម្រាប់បុគ្គលម្នាក់ៗ ជាមួយនឹងរយៈពេលនៃការធានារ៉ាប់រងរហូតដល់ 100 ឆ្នាំ។

## 4. តើអ្វីទៅជាកម្រិតអតិបរមាក្នុងមួយជីវិត?

ចំនួនអតិបរមាដែលនឹងបង់ជូនទៅកាន់អ្នកត្រូវបានធានារ៉ាប់រងនីមួយៗសម្រាប់មួយជីវិតនៃការធានា។ កម្រិតអតិបរមាក្នុងមួយជីវិតនៃផលិតផល AIA **សម្រាប់សុខភាព** គឺ 2 ដងនៃកម្រិតអតិបរមាប្រចាំឆ្នាំសរុប។

## 5. តើចំនួនទឹកប្រាក់ធានារ៉ាប់រងអប្បបរមាសម្រាប់អត្ថប្រយោជន៍លើមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍គឺប៉ុន្មាន?

ចំនួនទឹកប្រាក់ធានារ៉ាប់រងអប្បបរមាសម្រាប់អត្ថប្រយោជន៍លើមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍គឺ $5,000។

## 6. តើខ្ញុំអាចទិញផលិតផល AIA សម្រាប់សុខភាព ដោយភ្ជាប់វាទៅនឹងគម្រោងធានារ៉ាប់រងដែលខ្ញុំមានស្រាប់ដែរឬទេ?

ទេ អ្នកមិនអាចភ្ជាប់ផលិតផល AIA **សម្រាប់សុខភាព** ទៅនឹងគម្រោងធានារ៉ាប់រងដែលអ្នកមានស្រាប់បានទេ។ បច្ចុប្បន្ននេះ អ្នកអាចភ្ជាប់ផលិតផល AIA **សម្រាប់សុខភាព** ទៅនឹងផលិតផល AIA **ចម្បង** ដើម្បីទទួលបានការធានារ៉ាប់រងលើថ្លៃព្យាបាល។

FOR INTERNAL USE ONLY

## 7. តើខ្ញុំមានប៉ុន្មានជម្រើសដើម្បីបង់បុព្វលាភធានារ៉ាប់រងរបស់ខ្ញុំ?

អ្នកមាន 2 ជម្រើសដើម្បីបង់បុព្វលាភធានារ៉ាប់រងរបស់អ្នក - ប្រចាំឆ្នាំ (រៀងរាល់ 1 ឆ្នាំម្តង) និងប្រចាំឆមាស (រៀងរាល់ 6 ខែម្តង)។ ប្រសិនបើអ្នកបង់បុព្វលាភធានារ៉ាប់រងជាប្រចាំឆ្នាំ បុព្វលាភធានារ៉ាប់រងរបស់អ្នកនឹងតិចជាងសម្រាប់គម្រោងដូចគ្នា។

## 8. តើអ្វីទៅជា "រយៈពេលនៃការរងចាំ"? តើវាប្រព្រឹត្តទៅយ៉ាងដូចម្តេច?

រយៈពេលនៃការរងចាំគឺជារយៈពេលមួយក្នុងកំឡុងពេលដែលការព្យាបាលមិនត្រូវបានធានាក្រោមបណ្ណសន្យារ៉ាប់រងនេះ។ ចាប់ផ្តើមពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញចុងក្រោយបំផុត (បើមាន) ឬកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រងនៃគម្រោងដែលបានផ្លាស់ប្តូរថ្មី (បើមាន) ដោយយកកាលបរិច្ឆេទណាមួយចុងក្រោយគេ។ នៅក្រោមផលិតផលនេះ យើងមានរយៈពេលនៃការរងចាំចំនួន 4 ប្រភេទ:

- ការព្យាបាលបង្កឡើងពីជំងឺជាក់លាក់ណាមួយ: 120 ថ្ងៃ
- ការព្យាបាលបង្កឡើងពីជំងឺផ្សេងៗ (លើកលែងជំងឺជាក់លាក់): 30 ថ្ងៃ
- អត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូន: 18 ខែ
- អត្ថប្រយោជន៍លើការព្យាបាលបង្កឡើងពី ឬដោយពាក់ព័ន្ធនឹងមេរោគអេដស៍ (HIV) ឬជំងឺអេដស៍ (AIDS): 24 ខែ

ឧទាហរណ៍: រយៈពេលនៃការរងចាំសម្រាប់អត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូនគឺ 18 ខែ។ ដូច្នេះ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមានផ្ទៃពោះ និងសម្រាលកូនក្នុងរយៈពេល 18 ខែ គិតចាប់ពីកាលបរិច្ឆេទនៃសុពលភាពបណ្ណសន្យារ៉ាប់រង ក្រុមហ៊ុននឹងមិនធានារ៉ាប់រងសម្រាប់ការចំណាយក្រោមអត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូនទេ ព្រោះវាស្ថិតក្នុងរយៈពេលរង់ចាំ។

## 9. តើអ្វីទៅជារយៈពេលពិចារណាចុងក្រោយ?

រយៈពេលពិចារណាចុងក្រោយគឺជារយៈពេលដែលអ្នកមានសិទ្ធិក្នុងការបញ្ចប់បណ្ណសន្យារ៉ាប់រងនេះ ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរមកកាន់ក្រុមហ៊ុន។ ក្រុមហ៊ុន នឹងបង់សងជូនអ្នកវិញនូវបុព្វលាភធានារ៉ាប់រងដែលអ្នកបានបង់ហើយ បន្ទាប់ពីធ្វើការទូទាត់ជាមួយនឹងចំណាយនានាពាក់ព័ន្ធនឹងការពិនិត្យសុខភាព និងការចេញបណ្ណសន្យារ៉ាប់រង។ ការជូនដំណឹងនេះ ត្រូវធ្វើឡើងដោយអ្នក នៅក្នុងទម្រង់ដែលក្រុមហ៊ុនបានកំណត់ជូន ហើយត្រូវទទួលដោយក្រុមហ៊ុនដោយផ្ទាល់ក្នុងកំឡុងពេល 21 (ម្ភៃមួយ) ថ្ងៃនៃថ្ងៃប្រតិទិនបន្ទាប់ពីកាលបរិច្ឆេទចេញបណ្ណសន្យារ៉ាប់រង។

## 10. តើអ្វីទៅជារយៈពេលអនុគ្រោះ?

រយៈពេលអនុគ្រោះគឺជារយៈពេល 30 (សាមសិប) ថ្ងៃនៃថ្ងៃប្រតិទិន គិតចាប់ពីកាលបរិច្ឆេទដល់កំណត់បង់នឹងត្រូវបានអនុញ្ញាតសម្រាប់ការបង់បុព្វលាភធានារ៉ាប់រងបន្ទាប់។ បណ្ណសន្យារ៉ាប់រងនេះ នឹងបន្តមាន

FOR INTERNAL USE ONLY

សុពលភាពក្នុងកំឡុងរយៈពេលអនុគ្រោះនេះ។ ប្រសិនបើមានបុព្វលាភធានារ៉ាប់រងណាមួយ មិនទាន់បាន បង់នៅពេលផុតរយៈពេលអនុគ្រោះ បណ្ណសន្យារ៉ាប់រងនេះនឹងអស់សុពលភាព និងលែងមានតម្លៃ ហើយ ក្រុមហ៊ុនមិនត្រូវមានកាតព្វកិច្ចក្នុងការផ្តល់ជូននូវអត្ថប្រយោជន៍ដែលមាននៅក្រោមបណ្ណសន្យារ៉ាប់រងនេះ។

## II. ទីតាំងភូមិសាស្ត្រនៃការធានា

### 11. តើអ្វីទៅជាទីតាំងភូមិសាស្ត្រនៃការធានា?

គម្រោងនីមួយៗមានទីតាំងភូមិសាស្ត្រជាក់លាក់ដែលសំដៅលើកញ្ចប់នៃបណ្តាប្រទេសជាក់លាក់ដែលអ្នក អាចទទួលបានការព្យាបាល។

### 12. ហេតុអ្វីបានជាផលិតផលនេះមិនការពារនៅសហរដ្ឋអាមេរិក?

ហេតុផលចម្បងសម្រាប់ការមិនរាប់បញ្ចូលសហរដ្ឋអាមេរិកក្នុងការការពារគឺយើងចង់ផ្តល់តម្លៃសមរម្យ។ ការចំណាយលើការថែទាំសុខភាពនៅសហរដ្ឋអាមេរិកគឺស្ថិតក្នុងចំណោមតម្លៃខ្ពស់បំផុតក្នុងពិភពលោក។ យើងមិនអាចផ្តល់ការធានារ៉ាប់រងសម្រាប់តំបន់នេះដោយគ្មានការដំឡើងថ្លៃបុព្វលាភធានារ៉ាប់រងទៅកាន់ អតិថិជនរបស់យើងទេ។

### 13. តើផលិតផលនេះការពារលើការសង្គ្រោះបន្ទាន់ទូទាំងពិភពលោកដែរឬទេ?

ផលិតផលនេះការពារលើការសង្គ្រោះបន្ទាន់ដែលបង្កឡើងពីគ្រោះថ្នាក់ចៃដន្យទូទាំងពិភពលោក។

## III. គម្រោងគ្រួសារ

### 14. ប្រសិនបើខ្ញុំទិញផលិតផល AIA សម្រាប់សុខភាព សម្រាប់សមាជិកគ្រួសាររបស់ខ្ញុំ តើពួក យើងអាចស្ថិតក្រោមបណ្ណសន្យារ៉ាប់រងតែមួយដែរឬទេ?

អ្នកអាចទិញផលិតផល AIA **សម្រាប់សុខភាព** កញ្ចប់គ្រួសារសម្រាប់សមាជិកគ្រួសាររបស់អ្នក ដើម្បីឱ្យ គ្រួសាររបស់អ្នកទាំងអស់ការពារក្រោមបណ្ណសន្យារ៉ាប់រងតែមួយ។ ដោយត្រូវអនុលោមតាម ខ និង លក្ខខណ្ឌសម្រាប់ផលិតផល។

### 15. សម្រាប់គម្រោងគ្រួសារ តើសមាជិកអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗទទួលបានកាតធានា រ៉ាប់រងផ្ទាល់ខ្លួនដែរឬទេ?

សមាជិកអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗនឹងមានកាតផ្ទាល់ខ្លួន។

FOR INTERNAL USE ONLY

## 16. សម្រាប់គម្រោងគ្រួសារ ប្រសិនបើមានសមាជិក 5 នាក់ក្នុងបណ្ណសន្យារ៉ាប់រងតែមួយ ហើយសមាជិកខ្លះបានប្រើប្រាស់អស់កម្រិតអតិបរមាសរុបសម្រាប់មួយជីវិត តើក្នុងករណីនេះនឹងមានអ្វីកើតឡើងចំពោះបណ្ណសន្យារ៉ាប់រងទាំងមូល?

បណ្ណសន្យារ៉ាប់រងទាំងមូលនឹងបន្តការពារលើសមាជិកដែលនៅសល់ ដរាបណាដែលការធានារ៉ាប់រងមូលដ្ឋានរបស់អ្នកត្រូវបានធានារ៉ាប់រងគោល (មរណភាព/ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍) នៅតែមានសុពលភាព ពោលគឺអត្ថប្រយោជន៍លើមរណភាព/ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ មិនត្រូវបានទាមទារសំណង។

## 17. តើនឹងមានអ្វីកើតឡើងចំពោះគម្រោងគ្រួសារ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងគោលបានទទួលមរណភាព ឬទាមទារសំណងលើពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍?

បណ្ណសន្យារ៉ាប់រងទាំងមូល រួមទាំងផលិតផលធានារ៉ាប់រងបន្ថែមដែលភ្ជាប់មកជាមួយទាំងអស់ នឹងត្រូវបានបញ្ចប់បន្ទាប់ពីការទាមទារសំណងលើមរណភាព/ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ របស់អ្នកត្រូវបានធានារ៉ាប់រងគោល។ ពួកយើងកំពុងធ្វើការរៀបចំ ដើម្បីបន្តការធានារ៉ាប់រងសម្រាប់សមាជិកគ្រួសារផ្សេងទៀត នៅពេលដែលអ្នកត្រូវបានធានារ៉ាប់រងគោលទទួលមរណភាព។

# IV. ការចូលរួមចំណែកនៃការចំណាយ

## 18. តើអ្វីទៅជាការចូលរួមចំណែកនៃការចំណាយ?

ការចូលរួមចំណែកនៃការចំណាយគឺជាជម្រើសនៃការទូទាត់ដែលអាចអនុវត្តបានសម្រាប់គម្រោងដែលបានជ្រើសរើស នេះគឺជាចំនួនទឹកប្រាក់ដែលអ្នកត្រូវទទួលខុសត្រូវសម្រាប់ការចំណាយលើការថែទាំសុខភាព។ ការចូលរួមចំណែកនៃការចំណាយគឺ 10% នៃការចំណាយលើការព្យាបាលជាក់ស្តែងដែលការពារក្រោមផលិតផល AIA **សម្រាប់សុខភាព**។

អ្នកនឹងត្រូវចូលរួមចំណែកនៃការចំណាយសម្រាប់ការព្យាបាលនីមួយៗ រហូតដល់អ្នកឈានដល់កម្រិតអតិបរមាសម្រាប់ចំណាយពីហោប៉ៅផ្ទាល់ខ្លួន។ កម្រិតអតិបរមានេះគឺសម្រាប់ 1 ព្រឹត្តិការណ៍។ សម្រាប់ 1 ព្រឹត្តិការណ៍ សំដៅលើ ជំងឺ ឬរបួសណាមួយ ដែលបង្កពីមូលហេតុតែមួយ រួមបញ្ចូលផលវិបាកផ្សេងៗដែលពាក់ព័ន្ធ។

## 19. តើអ្វីទៅជាកម្រិតអតិបរមាសម្រាប់ចំណាយពីហោប៉ៅផ្ទាល់ខ្លួន?

ចំនួនទឹកប្រាក់ជាក់លាក់សម្រាប់ 1 ព្រឹត្តិការណ៍ដែលអ្នកត្រូវបានធានារ៉ាប់រងនឹងត្រូវទទួលខុសត្រូវនៅក្រោមជម្រើសការចូលរួមចំណែកនៃការចំណាយ។ នៅពេលដែលកម្រិតអតិបរមាសម្រាប់ចំណាយពីហោប៉ៅផ្ទាល់ខ្លួន ដល់កម្រិតអតិបរមាសម្រាប់ 1 ព្រឹត្តិការណ៍ អ្នកត្រូវបានធានារ៉ាប់រងនឹងមិនតម្រូវឱ្យទទួលខុសត្រូវលើចំណែកនៃចំណាយដែលត្រូវបង់ណាមួយសម្រាប់ព្រឹត្តិការណ៍តែមួយនោះឡើយ។

FOR INTERNAL USE ONLY

នៅក្នុងន័យនេះ សម្រាប់ 1 ព្រឹត្តិការណ៍គឺជាជំងឺ ឬរបួសណាមួយ ដែលបង្កពីមូលហេតុតែមួយ រួមបញ្ចូលផលវិបាកផ្សេងៗ ដែលពាក់ព័ន្ធ។

## 20. តើមានជម្រើសអោយខ្ញុំជ្រើសរើសភាគរយសម្រាប់គម្រោងការចូលរួមចំណែកនៃការចំណាយដែរឬទេ?

សម្រាប់គម្រោងការចូលរួមចំណែកនៃការចំណាយ យើងមានតែ 10% សម្រាប់គម្រោង 50K 150K 500K និង1M លើកលែងតែ គម្រោង 1.5M ដែលមិនមានការចូលរួមចំណែកនៃការចំណាយ។

## 21. ហេតុអ្វីបានជាអតិថិជនត្រូវបង់ការចូលរួមចំណែកនៃការចំណាយ10%?

ការចូលរួមចំណែកនៃការចំណាយជួយរក្សាបុព្វលាភធានារ៉ាប់រងអោយមានតម្លៃសមរម្យ។ ដោយតម្រូវឱ្យបុគ្គលម្នាក់ៗបង់ប្រាក់មួយផ្នែកតូចនៃថ្លៃថែទាំសុខភាព ការទាមទារសំណងដែលមិនចាំបាច់ ដូច្នេះហើយ តម្លៃសរុបនៃការថែទាំសុខភាពអាចត្រូវបានកាត់បន្ថយ។ នេះជួយរក្សាបុព្វលាភធានារ៉ាប់រងមិនឱ្យកើនឡើងច្រើនពេក។

## 22. តើអតិថិជនបង់ការចូលរួមចំណែកនៃការចំណាយនៅពេលណា?

- សម្រាប់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់: អ្នកនឹងបង់ការចូលរួមចំណែកនៃការចំណាយទៅមន្ទីរពេទ្យនៅពេលចេញពីមន្ទីរពេទ្យ ឬបញ្ចប់ការព្យាបាល។
- សម្រាប់ការទូទាត់ប្រាក់ត្រលប់មកវិញ: អ្នកនឹងបង់ថ្លៃព្យាបាលរបស់អ្នកជាមុនសិន បន្ទាប់មកទាមទារសំណងជាមួយក្រុមហ៊ុន AIA វិញ។ ក្រុមហ៊ុន AIA នឹងសងជូនវិញនូវចំណាយដែលមានលក្ខខណ្ឌគ្រប់គ្រាន់ បន្ទាប់ពីបានកាត់ចំនួនទឹកប្រាក់នៃការចូលរួមចំណែកនៃការចំណាយរួចរាល់។

## 23. តើអត្ថប្រយោជន៍លើមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍មានការចូលរួមចំណែកនៃការចំណាយដែរឬទេ?

ទេ យើងមិនមានការចូលរួមចំណែកនៃការចំណាយសម្រាប់អត្ថប្រយោជន៍លើមរណភាព និងពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ទេ។

FOR INTERNAL USE ONLY

# V. កម្រិតមិនធ្វើសំណង

## 24. តើអ្វីទៅជាកម្រិតមិនធ្វើសំណង?

កម្រិតមិនធ្វើសំណងគឺជាចំនួននៃចំណាយដែលមានលក្ខខណ្ឌគ្រប់គ្រាន់ ដែលអ្នកត្រូវចេញដោយខ្លួនឯងជាមុនសិន មុនពេលអត្ថប្រយោជន៍ណាមួយត្រូវបង់ដោយក្រុមហ៊ុននៅក្រោមបណ្ណសន្យារ៉ាប់រងនេះក្នុងឆ្នាំនៃបណ្ណសន្យារ៉ាប់រងនីមួយៗ។
ឧទាហរណ៍: ប្រសិនបើអ្នកទិញផលិតផល AIA **សម្រាប់សុខភាព** ជាមួយនឹងជម្រើសកម្រិតមិនធ្វើសំណងចំនួន $5,000 សម្រាប់រៀងរាល់ឆ្នាំនៃបណ្ណសន្យារ៉ាប់រងនីមួយៗ អ្នកនឹងត្រូវទទួលខុសត្រូវប្រាក់ចំនួន $5,000 ដំបូងនៃចំណាយដែលមានលក្ខខណ្ឌគ្រប់គ្រាន់ មុនពេលអត្ថប្រយោជន៍ណាមួយត្រូវបង់ក្រោមបណ្ណសន្យារ៉ាប់រងនេះ។ នៅពេលដែលកម្រិតមិនធ្វើសំណងដល់កម្រិត $5,000 ហើយ ក្រុមហ៊ុន AIA នឹងបង់ចំណាយដែលមានលក្ខខណ្ឌគ្រប់គ្រាន់ទាំងអស់សម្រាប់រយៈពេលដែលនៅសល់នៃឆ្នាំនៃបណ្ណសន្យារ៉ាប់រងនេះ រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំសរុប។

ឧទាហរណ៍: ប្រសិនបើអ្នកមានគម្រោងធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រដែលមានកម្រិតអតិបរមាប្រចាំឆ្នាំចំនួន $5,000 ដែលការពារដោយក្រុមហ៊ុនរបស់អ្នក ហើយអ្នកចង់ទិញផលិតផលធានារ៉ាប់រង AIA **សម្រាប់សុខភាព** គម្រោង 150K ជាមួយនឹងជម្រើសកម្រិតមិនធ្វើសំណង $5,000 ដើម្បីបន្ថែមពីលើធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្ររបស់អ្នក។ ដូច្នេះហើយ ជារៀងរាល់ឆ្នាំ អ្នកអាចប្រើគម្រោងធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្ររបស់ក្រុមហ៊ុនរបស់អ្នកដើម្បីបង់ 5,000 ដំបូងនៃចំណាយដែលមានលក្ខខណ្ឌគ្រប់គ្រាន់។ នៅពេលដែលកម្រិតមិនធ្វើសំណងដល់កម្រិត $5,000 ហើយ ក្រុមហ៊ុន AIA នឹងបង់ចំណាយដែលមានលក្ខខណ្ឌគ្រប់គ្រាន់ទាំងអស់សម្រាប់រយៈពេលដែលនៅសល់នៃឆ្នាំនៃបណ្ណសន្យារ៉ាប់រងនេះ រហូតដល់កម្រិតអតិបរមាប្រចាំឆ្នាំសរុប។

## 25. តើអ្នកណាខ្លះគួរទិញគម្រោងកម្រិតមិនធ្វើសំណង?

ជាទូទៅ គម្រោងកម្រិតមិនធ្វើសំណងរបស់យើងគឺសមស្របសម្រាប់បុគ្គលដែលមានការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រហើយស្រាប់ ដែលផ្តល់ដោយនិយោជករបស់ពួកគេ ហើយពួកគេចង់បន្ថែមការធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រជាមួយនឹងបុព្វលាភធានារ៉ាប់រងដែលមានតម្លៃសមរម្យ (ធូរថ្លៃ)។

ប្រសិនបើអតិថិជនមានលទ្ធភាព យើងណែនាំគម្រោងការចូលរួមចំណែកនៃការចំណាយព្រោះថាមនុស្សម្នាក់ៗនឹងចាកចេញពីការងារនៅពេលអាយុច្រើន ហើយមិនត្រូវបានធានារ៉ាប់រងផ្នែកវេជ្ជសាស្ត្រដោយក្រុមហ៊ុនទៀតទេ ក្នុងពេលជាមួយគ្នានោះតម្រូវការផ្នែកវេជ្ជសាស្ត្រនឹងកើនឡើងនៅពេលចាស់ទៅ។

FOR INTERNAL USE ONLY

## VI. ការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណង & កាបូបលុយសម្រាប់ការថែទាំសុខភាព

### 26. តើអ្វីទៅជាអត្ថប្រយោជន៍លើកទឹកចិត្តសម្រាប់ការមិនទាមទារសំណង?

ការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណងគឺជាចំនួនទឹកប្រាក់បូកបញ្ចូលទៅក្នុងកាបូបលុយសម្រាប់ការថែទាំសុខភាព (Health Wallet) របស់អ្នកជារៀងរាល់ឆ្នាំសម្រាប់ការមិនមានការទាមទារសំណងសរុបរហូតដល់ចំនួន 10 ដងក្នុងរយៈពេលនៃការធានារ៉ាប់រង។

ចំនួនទឹកប្រាក់នៃការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណង អនុលោមតាមគម្រោងដែលអ្នកបានជ្រើសរើសនឹងត្រូវបានបូកបញ្ចូលនៅដើមឆ្នាំនៃបណ្ណសន្យារ៉ាប់រង ប្រសិនបើមិនមានការទាមទារសំណងណាមួយ ត្រូវបានធ្វើឡើងនៅក្នុងកំឡុងឆ្នាំនៃបណ្ណសន្យារ៉ាប់រងមុននោះទេ។

ការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណងផ្តល់ឱ្យអ្នកនូវអត្ថប្រយោជន៍បន្ថែមដែលអាចរួមបញ្ចូលការថែទាំដើម្បីបង្ការជំងឺផ្សេងៗ និងការថែទាំសុខភាពមាត់ធ្មេញ។

### 27. តើខ្ញុំអាចប្រើប្រាស់អត្ថប្រយោជន៍លើកទឹកចិត្តសម្រាប់ការមិនទាមទារសំណងបានយ៉ាងដូចម្តេច?

ប្រសិនបើគម្រោងដែលអ្នកបានទិញមានការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណងចំនួន $150 ក្នុងមួយឆ្នាំ ហើយអ្នកមិនបានធ្វើការទាមទារណាមួយសម្រាប់ពេញមួយឆ្នាំនេះ អ្នកនឹងមានទឹកប្រាក់ចំនួន $150 ក្នុងកាបូបលុយសម្រាប់ការថែទាំសុខភាព (Health Wallet) របស់អ្នកនៅឆ្នាំបន្ទាប់។ ដូច្នេះ អ្នកអាចប្រើវាសម្រាប់ធ្វើការពិនិត្យសុខភាពជាប្រចាំ ការត្រួតពិនិត្យរកជំងឺផ្សេងៗ ការចាក់ថ្នាំបង្ការ ឬការថែទាំ និងពិនិត្យសុខភាពមាត់ធ្មេញជាប្រចាំ (ដែលជាអត្ថប្រយោជន៍ដែលទទួលការអនុញ្ញាតក្រោម កាបូបលុយសម្រាប់ការថែទាំសុខភាព (Health Wallet) ដែលបានចែងនៅក្នុងតារាងអត្ថប្រយោជន៍)។

### 28. តើខ្ញុំអាចដកប្រាក់នៅក្នុងកាបូបលុយសម្រាប់ការថែទាំសុខភាពបានដែរឬ?

ទេ ទឹកប្រាក់នៅក្នុងកាបូបលុយសម្រាប់ការថែទាំសុខភាពគឺសម្រាប់ជួយអ្នកក្នុងការថែរក្សាសុខភាពរបស់អ្នក។ វាអាចប្រើប្រាស់បានសម្រាប់តែការពិនិត្យសុខភាពជាប្រចាំ ការត្រួតពិនិត្យរកជំងឺផ្សេងៗ ការចាក់ថ្នាំបង្ការ ឬការថែទាំ និងពិនិត្យសុខភាពមាត់ធ្មេញជាប្រចាំ។ នៅពេលមានការទាមទារសំណងលើមរណភាព ទឹកប្រាក់ដែលនៅសល់នឹងត្រូវសងទៅអ្នកទទួលផល រួមជាមួយនឹងអត្ថប្រយោជន៍លើមរណភាព។ ប៉ុន្តែ ប្រសិនបើ បណ្ណសន្យារ៉ាប់រងត្រូវបានលុបចោល នោះទឹកប្រាក់ដែលមានក្នុងកាបូបលុយសម្រាប់ការថែទាំសុខភាព នឹងមិនត្រូវបានបង្វិលសងវិញទេ។

FOR INTERNAL USE ONLY

29. **តើខ្ញុំត្រូវបង់ការចូលរួមចំណែកនៃការចំណាយ 10% សម្រាប់អត្ថប្រយោជន៍ការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណងដែរឬទេ?**

ទេ អ្នកមិនចាំបាច់បង់ 10% សម្រាប់អត្ថប្រយោជន៍ការលើកទឹកចិត្តសម្រាប់ការមិនទាមទារសំណងទេ។ ការចូលរួមចំណែកនៃការចំណាយ 10% គឺតម្រូវសម្រាប់តែការទាមទារសំណងលើអត្ថប្រយោជន៍គោលប៉ុណ្ណោះ (អត្ថប្រយោជន៍លើការសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ និងការវះកាត់ អត្ថប្រយោជន៍លើការព្យាបាលជំងឺដែលមិនចាំបាច់សម្រាកក្នុងមន្ទីរពេទ្យ អត្ថប្រយោជន៍លើការព្យាបាលជំងឺសង្គ្រោះបន្ទាន់ អត្ថប្រយោជន៍លើថ្លៃព្យាបាលពេលសម្រាលកូន និងអត្ថប្រយោជន៍លើការព្យាបាលបង្កឡើងពី ឬដោយពាក់ព័ន្ធនឹងវីរុសហ៊ីវ (HIV) ឬជំងឺអេដស៍ (AIDS))។

30. **នៅក្រោមកញ្ចប់គ្រួសារ តើអ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗមានកាបូបលុយសម្រាប់ការថែទាំសុខភាពរៀងៗខ្លួនដែរឬទេ?**

អ្នកត្រូវបានធានារ៉ាប់រងម្នាក់ៗមានកាបូបលុយសម្រាប់ការថែទាំសុខភាពរៀងៗខ្លួនទៅតាមគម្រោងដែលពួកគេបានជ្រើសរើស។

31. **នៅក្រោមកញ្ចប់គ្រួសារ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងគោលបានធ្វើការទាមទារសំណងលើអត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ តើវានឹងប៉ះពាល់ដល់កាបូបសម្រាប់ការថែទាំសុខភាពរបស់សមាជិកគ្រួសារផ្សេងទៀតដែរឬទេ?**

ទេ អ្នកត្រូវបានធានារ៉ាប់រងនីមួយៗមានការការពារផ្ទាល់ខ្លួនទៅតាមគម្រោងដែលពួកគេបានជ្រើសរើស។ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងម្នាក់ធ្វើការទាមទារសំណងលើអត្ថប្រយោជន៍ផ្នែកវេជ្ជសាស្ត្រ នោះមានតែកម្រិតអតិបរមា និងអត្ថប្រយោជន៍នៃការធានារ៉ាប់រងផ្ទាល់ខ្លួនរបស់អ្នកត្រូវបានធានារ៉ាប់រងម្នាក់នោះប៉ុណ្ណោះដែលត្រូវរងផលប៉ះពាល់។

## VII. បុព្វលាភធានារ៉ាប់រង

32. **តើបុព្វលាភធានារ៉ាប់រងរបស់ផលិតផលនេះថេរក្នុងកំឡុងពេលនៃការធានារ៉ាប់រងដែរឬទេ?**

ទេ បុព្វលាភធានារ៉ាប់រងរបស់ផលិតផល AIA **សម្រាប់សុខភាព** មិននៅស្ថិតស្ថេរ និងមិនត្រូវបានធានាឡើយ។ បុព្វលាភធានារ៉ាប់រងនឹងកើនឡើងជារៀងរាល់ឆ្នាំទៅតាមអាយុរបស់អ្នកត្រូវបានធានារ៉ាប់រងដូចបានបង្ហាញក្នុងសំណើធានារ៉ាប់រង។ បុព្វលាភធានារ៉ាប់រងនឹងមានការកែសម្រួលពីមួយឆ្នាំទៅមួយឆ្នាំដោយមើលទៅលើអតិផរណាផ្នែកវេជ្ជសាស្ត្រ និងតម្លៃកើនឡើងទូទៅនៃការព្យាបាល សម្ភារៈ ឬសេវាវេជ្ជសាស្ត្រ។

FOR INTERNAL USE ONLY

## 33. តើអ្វីទៅធ្វើឱ្យបុព្វលាភធានារ៉ាប់រងនៃគម្រោងវេជ្ជសាស្ត្រកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ?

ការកើនឡើងនៃបុព្វលាភធានារ៉ាប់រងនៃគម្រោងវេជ្ជសាស្ត្រគឺដោយសារតែពីរហេតុផល: (1) ការកើនឡើងនៃអាយុរបស់អ្នកត្រូវបានធានារ៉ាប់រង (2) ការកំណត់តម្លៃឡើងវិញដោយក្រុមហ៊ុនដើម្បីឆ្លុះបញ្ចាំងពីនិន្នាការចុងក្រោយបំផុតនៃថ្លៃព្យាបាល។

## 34. ហេតុអ្វីបានជាបុព្វលាភធានារ៉ាប់រងនៃគម្រោងវេជ្ជសាស្ត្រមិនត្រូវបានធានា?

បុព្វលាភធានារ៉ាប់រងនៃគម្រោងវេជ្ជសាស្ត្រគឺផ្អែកលើការប្រើប្រាស់ និងតម្លៃនៃសេវាវេជ្ជសាស្ត្រ ដែលស្ថិតក្រោមកត្តាមួយចំនួនដូចជា ការកើនឡើងនូវថ្លៃព្យាបាល ការកើនឡើងនូវតម្រូវការសម្រាប់សេវាថែទាំសុខភាព អតិផរណា និងភាពជឿនលឿននៃបច្ចេកវិទ្យាវេជ្ជសាស្ត្រ។ កត្តាទាំងនេះពិបាកនឹងទាយទុកជាមុនដូច្នេះហើយបុព្វលាភធានារ៉ាប់រងមិនអាចធានាបានទេ។

## 35. តើការបន្តសុពលភាពប្រចាំឆ្នាំសម្រាប់ផលិតផលនេះត្រូវបានធានាដែរឬទេ?

បណ្ណសន្យារ៉ាប់រងនេះត្រូវបានធានាបន្តសុពលភាពជារៀងរាល់ឆ្នាំនៅខួបនៃបណ្ណសន្យារ៉ាប់រងដោយបង់បុព្វលាភធានារ៉ាប់រងជាមុន មុនចុងបញ្ចប់នៃរយៈពេលអនុគ្រោះ។ បុព្វលាភរ៉ាប់រងបន្តបន្ទាប់គឺផ្អែកលើអាយុនៅថ្ងៃកំណើតបន្ទាប់របស់អ្នកត្រូវបានធានារ៉ាប់រងនៅខួបនៃបណ្ណសន្យារ៉ាប់រងនៅអត្រាបុព្វលាភដែលបានកំណត់ដោយយើងនៅកាលបរិច្ឆេទនៃការបន្តសុពលភាព។

## 36. ប្រសិនបើខ្ញុំទាមទារសំណងច្រើនក្នុងមួយឆ្នាំនៃបណ្ណសន្យារ៉ាប់រង តើក្រុមហ៊ុន AIA នឹងឈប់បន្តបណ្ណសន្យារ៉ាប់រងរបស់ខ្ញុំ ឬដំឡើងបុព្វលាភធានារ៉ាប់រងរបស់ខ្ញុំឱ្យច្រើនឡើងនៅឆ្នាំបន្ទាប់ដែរឬទេ?

ក្រុមហ៊ុន AIA នឹងបន្តបណ្ណសន្យារ៉ាប់រងរបស់អ្នក ទោះបីជាអ្នកអកុសលធ្លាក់ខ្លួនឈឺនូវថ្ងៃណាមួយ ហើយត្រូវការទាមទារសំណងថ្លៃព្យាបាលយ៉ាងច្រើនពីបណ្ណសន្យារ៉ាប់រងរបស់អ្នកក៏ដោយ។ មិនមានបុព្វលាភធានារ៉ាប់រងបន្ថែមណាត្រូវបានបញ្ចូលទៅក្នុងបុព្វលាភធានារ៉ាប់រងបន្តរបស់អ្នកដោយសារតែការទាមទារសំណងរបស់អ្នកនោះឡើយ។ បុព្វលាភធានារ៉ាប់រងបន្តបន្ទាប់ទៀតនាពេលអនាគតអាចត្រូវបានកែតម្រូវដោយក្រុមហ៊ុនដើម្បីឆ្លុះបញ្ចាំងពីអតិផរណាផ្នែកវេជ្ជសាស្ត្រ និងបទពិសោធន៍នៃការទាមទារសំណង ប៉ុន្តែវាស្ថិតនៅលើកម្រិតទីផ្សារទាំងមូល និងមិនមែនផ្អែកលើបុគ្គលម្នាក់ៗនោះទេ។

FOR INTERNAL USE ONLY

## VIII. ការផ្លាស់ប្តូរបណ្ណសន្យារ៉ាប់រង

### 37. តើអតិថិជនអាចបំប្លែងគម្រោងវេជ្ជសាស្រ្តដែលមានស្រាប់របស់ពួកគេទៅជាគម្រោងមួយផ្សេងទៀតដែរឬទេ?

អតិថិជនអាចបំប្លែងទៅជាផលិតផលធានារ៉ាប់រងបន្ថែមគម្រោងវេជ្ជសាស្រ្តផ្សេងទៀតដោយដាក់សំណើមុននៅខួបនៃបណ្ណសន្យារ៉ាប់រង។ គម្រោងថ្មីនឹងមានសុពលភាពចាប់ពីខួបនៃបណ្ណសន្យារ៉ាប់រងបន្ទាប់។ អត្ថប្រយោជន៍ ខ និងលក្ខខណ្ឌ និងបុព្វលាភធានារ៉ាប់រងនៅក្រោមផលិតផលធានារ៉ាប់រងនេះនឹងត្រូវផ្លាស់ប្តូរ។

ការបំប្លែងខាងក្រោមនេះត្រូវបានចាត់ទុកជាការដំឡើងគម្រោង និងត្រូវមានការវាយតម្លៃហានិភ័យបន្ថែម:

| **ការបំប្លែងគម្រោង** | **ឧទាហរណ៍** |
|---|---|
| ដំឡើងគម្រោង | ផ្លាស់ប្តូរពីគម្រោង 50K ទៅគម្រោង 150K |
| បន្ថយក្នុងកម្រិតមិនធ្វើសំណងនូវគម្រោងដដែល | ផ្លាស់ប្តូរពីគម្រោង 50K ជាមួយនឹងកម្រិតមិនធ្វើសំណងចំនួន $10,000 ទៅគម្រោង 50K ជាមួយនឹងកម្រិតមិនធ្វើសំណងចំនួន USD5,000 |
| ការផ្លាស់ប្តូរពីកម្រិតមិនធ្វើសំណង ទៅការចូលរួមចំណែកនៃការចំណាយ ឬការមិនចូលរួមចំណែកនៃការចំណាយនូវគម្រោងដដែល | ផ្លាស់ប្តូរពីគម្រោង 50K ជាមួយនឹងកម្រិតមិនធ្វើសំណងចំនួន $5,000 ទៅគម្រោង 50K ជាមួយ 10% ការចូលរួមចំណែកនៃការចំណាយ |

### 38. តើរយៈពេលនៃការរងចាំត្រូវបានអនុវត្តយ៉ាងដូចម្តេចបន្ទាប់ពីការបំប្លែងគម្រោង?

រយៈពេលនៃការរង់ចាំត្រូវអនុវត្តចំពោះអត្ថប្រយោជន៍ដែលកើនឡើង ឬបន្ថែមបន្ទាប់ពីការបំប្លែងគម្រោងដោយចាប់ផ្តើមពីកាលបរិច្ឆេទមានសុពលភាពនៃគម្រោងថ្មី។

ឧទាហរណ៍: ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងបំប្លែងពីគម្រោង 50K ទៅជាគម្រោង 500K រយៈពេលនៃការរង់ចាំ 18 ខែនឹងត្រូវអនុវត្តចំពោះ "អត្ថប្រយោជន៍លើការសម្រាលកូន និងការថែទាំទារកទើបនឹងកើត" ចាប់ពីកាលបរិច្ឆេទមានសុពលភាពនៃគម្រោង 500K ដោយសារតែអត្ថប្រយោជន៍នេះមិនត្រូវបានការពារក្រោមគម្រោងចាស់ (Plan 50K)។

### 39. ប្រសិនបើខ្ញុំបានស្នើសុំដំឡើងគម្រោង ហើយត្រូវបានច្រានចោល តើខ្ញុំនៅតែអាចបន្តជាមួយគម្រោងដែលមានស្រាប់របស់ខ្ញុំបានដែរឬទេ?

អ្នកនៅតែអាចបន្តប្រើប្រាស់គម្រោងដែលមានស្រាប់របស់អ្នកបាន។

FOR INTERNAL USE ONLY

## 40. តើកម្រិតអតិបរមាក្នុងមួយជីវិតនឹងបង្ហាញយ៉ាងដូចម្តេចសម្រាប់មួយរយៈពេលនៃការធានារ៉ាប់រង?

ឧទាហរណ៍នៃដំណើរការកម្រិតអតិបរមាក្នុងមួយជីវិតមានបង្ហាញដូចខាងក្រោម៖

លោក A ទិញផលិតផលធានារ៉ាប់រង AIA សម្រាប់សុខភាព គម្រោង 500K ហើយកម្រិតអតិបរមាក្នុងមួយជីវិតរបស់គាត់គឺ $1M។

| | ឆ្នាំទី1 | ឆ្នាំទី5 | ឆ្នាំទី15 | ឆ្នាំទី30 | ឆ្នាំទី50 | ឆ្នាំទី70 |
|---|---|---|---|---|---|---|
| | ក្នុងឆ្នាំទី1 មិនមានការទាមទារណាមួយត្រូវបានធ្វើឡើងទេ។ ដូច្នេះ កម្រិតអតិបរមាក្នុងមួយជីវិតរបស់លោក A នៅសល់ចំនួន $1M។ | នៅចន្លោះឆ្នាំទី 2 ដល់ទី 5 លោក A បានទាមទារសំណងចំនួន $150K។ ដូច្នេះ កម្រិតអតិបរមាក្នុងមួយជីវិតរបស់គាត់ត្រូវបានកាត់បន្ថយមកត្រឹម $850K។ | នៅចន្លោះឆ្នាំទី 6 ដល់ទី 15 លោក A បានទាមទារសំណងចំនួន $300K។ ដូច្នេះ កម្រិតអតិបរមាក្នុងមួយជីវិតរបស់គាត់ត្រូវបានកាត់បន្ថយមកត្រឹម $550K។ | នៅចន្លោះឆ្នាំទី16 ដល់ទី 30 លោក A បានទាមទារសំណងចំនួន $200K។ ដូច្នេះ កម្រិតអតិបរមាក្នុងមួយជីវិតរបស់គាត់ត្រូវបានកាត់បន្ថយមកត្រឹម $350K។ | នៅចន្លោះឆ្នាំទី 31 ដល់ទី 50 លោក A បានទាមទារសំណងចំនួន $100K។ ដូច្នេះ កម្រិតអតិបរមាក្នុងមួយជីវិតរបស់គាត់ត្រូវបានកាត់បន្ថយមកត្រឹម $250K។ | នៅចន្លោះឆ្នាំទី 51 ដល់ទី 70 លោក A បានទាមទារសំណងចំនួន $250K។ ដូច្នេះ គាត់បានប្រើអស់កម្រិតអតិបរមាក្នុងមួយជីវិតរបស់គាត់។ |
| **កម្រិតអតិបរមាប្រចាំឆ្នាំ** | $500K | $500K | $500K | $500K | $350K | $250K |
| **សំណងដែលបានបង់ជូន** | $0K | $150K | $300K | $200K | $100K | $250K |
| **កម្រិតអតិបរមាប្រចាំឆ្នាំដែលនៅសល់** | $500K | $350K | $200K | $300K | $250K | $0K |
| **កម្រិតអតិបរមាក្នុងមួយជីវិត** | $1M | $850K | $550K | $350K | $250K | $0K |

FOR INTERNAL USE ONLY

## 41. តើកម្រិតអតិបរមាក្នុងមួយជីវិតនឹងទៅជាយ៉ាងណាបន្ទាប់ពីការបំប្លែងគម្រោង?

ប្រសិនបើដំបូង អ្នកត្រូវបានធានារ៉ាប់រងទិញគម្រោង 50K ហើយទាមទារសំណងអស់ $20K ក្នុងរយៈពេល 2 ឆ្នាំដំបូង ហើយបន្ទាប់មកបានដំឡើងគម្រោងដោយជោគជ័យទៅគម្រោង 500K ក្នុងឆ្នាំទី 3 នោះ កម្រិតអតិបរមាក្នុងមួយជីវិតបន្ទាប់ពីការដំឡើងគម្រោងគឺ: ($500K x 2) – $20K = $980K។

## 42. តើខ្ញុំអាចផ្លាស់ប្តូររបៀបបង់បុព្វលាភធានារ៉ាប់រងបានទេ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងនេះចូលជាធរមាន?

អ្នកអាចផ្លាស់ប្តូររបៀបបង់បុព្វលាភធានារ៉ាប់រងបានដោយដាក់សំណើមុនខួបនៃបណ្ណសន្យារ៉ាប់រង។ របៀបបង់បុព្វលាភធានារ៉ាប់រងថ្មីនឹងមានសុពលភាពចាប់ពីខួបនៃបណ្ណសន្យារ៉ាប់រងបន្ទាប់។

# IX. ការទាមទារសំណង

## 43. តើខ្ញុំដាក់ពាក្យទាមទារសំណងបានដោយរបៀបណា?

អ្នកអាចដាក់ពាក្យទាមទារសំណងបានតាមរយៈ:

- គេហទំព័រសម្រាប់អតិថិជន
- តេឡេក្រាម AIACambodia_bot (https://t.me/AIACambodia_bot)
- ទាក់ទងទៅសេវាបម្រើអតិថិជន / ទីប្រឹក្សាផែនការជីវិត/ ភ្នាក់ងារ

## 44. តើឯកសារអ្វីខ្លះដែលខ្ញុំត្រូវមានសម្រាប់ការទាមទារសំណងប្រាក់ត្រលប់មកវិញ?

ឯកសារដែលអ្នកត្រូវមានគឺ:

| អ្នកត្រូវបានធានារ៉ាប់រង | ភ្នាក់ងារ/ ទីប្រឹក្សាផែនការជីវិត តំណាងឱ្យអ្នកត្រូវបានធានារ៉ាប់រង |
|---|---|
| 1. វិញ្ញាបណ្ណប័ត្រវេជ្ជសាស្ត្រ /ឯកសារធ្វើតេស្តរោគវិនិច្ឆ័យ/ របាយការណ៍ពីវេជ្ជបណ្ឌិត/ វេជ្ជបញ្ជា*<br>2. លិខិតចេញពីមន្ទីរពេទ្យ (ប្រសិនបានសម្រាកព្យាបាលនៅមន្ទីរពេទ្យ)**<br>3. វិក្កយបត្រ លម្អិតការចំណាយជាក់ស្តែង*<br>4. លទ្ធផលនៃការធ្វើតេស្តរោគវិនិច្ឆ័យនៅមន្ទីរពិសោធន៍**<br>5. ឯកសារផ្សេងៗ | 1. វិញ្ញាបណ្ណប័ត្រវេជ្ជសាស្ត្រ /ឯកសារធ្វើតេស្តរោគវិនិច្ឆ័យ/ របាយការណ៍ពីវេជ្ជបណ្ឌិត/ វេជ្ជបញ្ជា*<br>2. លិខិតចេញពីមន្ទីរពេទ្យ (ប្រសិនបានសម្រាកព្យាបាលនៅមន្ទីរពេទ្យ)**<br>3. វិក្កយបត្រ លម្អិតការចំណាយជាក់ស្តែង*<br>4. លទ្ធផលនៃការធ្វើតេស្តរោគវិនិច្ឆ័យនៅមន្ទីរពិសោធន៍**<br>5. ភស្តុតាងព័ត៌មានគណនីធនាគាររបស់អ្នកត្រូវបានធានារ៉ាប់រង* |

FOR INTERNAL USE ONLY

** ឯកសារតម្រូវ។*
*** ឯកសារតម្រូវករណីអ្នកជំងឺបានសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬ ការធ្វើតេស្តរោគវិនិច្ឆ័យ។*

## 45. តើឯកសារអ្វីខ្លះដែលខ្ញុំត្រូវមានដើម្បីប្រើប្រាស់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់នៅមន្ទីរពេទ្យដៃគូរក្នុងស្រុករបស់ក្រុមហ៊ុន AIA?

អ្នកត្រូវមានកាតធានារ៉ាប់រងផ្នែកវេជ្ជសាស្រ្តរបស់អ្នក (virtual ឬ physical) និងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែន ដើម្បីប្រើប្រាស់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់នៅមន្ទីរពេទ្យដៃគូររបស់យើង។

## 46. តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីប្រើប្រាស់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់នៅមន្ទីរពេទ្យដៃគូរក្រៅស្រុករបស់ក្រុមហ៊ុន AIA?

ដើម្បីប្រើប្រាស់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់នៅមន្ទីរពេទ្យដៃគូរក្រៅស្រុករបស់ក្រុមហ៊ុន AIA នេះគឺជាជំហានដែលអ្នកត្រូវធ្វើ:

1. ទាក់ទងទៅទីប្រឹក្សាផែនការជីវិត ឬភ្នាក់ងារ ឬសេវាបម្រើអតិថិជន ឬតេឡេក្រាម AIACambodia_bot (https://t.me/AIACambodia_bot)
2. បំពេញទម្រង់បែបបទការស្នើសុំការអនុញ្ញាតជាមុន
3. ផ្ញើទម្រង់បែបបទការស្នើសុំការអនុញ្ញាតជាមុនជាមួយឯកសារវេជ្ជសាស្រ្តផ្សេងទៅក្រុមហ៊ុន AIA អ៊ីមែល kh.claim@aia.com ឬតាមរយៈតេឡេក្រាម AIACambodia_bot (https://t.me/AIACambodia_bot)

អ្នកត្រូវបានធានារ៉ាប់រងត្រូវជូនដំណឹងមកកាន់ក្រុមហ៊ុន AIA យ៉ាងតិច 5 ថ្ងៃនៃថ្ងៃធ្វើការមុននឹងនីតិវិធី ឬ កាលបរិច្ឆេទព្យាបាល។

## 47. តើខ្ញុំអាចទទួលបានទម្រង់បែបបទការស្នើសុំការអនុញ្ញាតជាមុននៅឯណា?

អ្នកអាចទាក់ទងទៅសេវាបម្រើអតិថិជន ទូរស័ព្ទលេខ 086 999 242 ឬទាក់ទងទៅទីប្រឹក្សាផែនការជីវិត/ភ្នាក់ងារ/ តេឡេក្រាម AIACambodia_bot (https://t.me/AIACambodia_bot)។ បន្ទាប់មកក្រុមហ៊ុន AIA នឹងផ្ញើទម្រង់បែបបទការស្នើសុំការអនុញ្ញាតជាមុនទៅអ្នកដើម្បីបំពេញ។

## 48. ខ្ញុំមានគម្រោងទៅព្យាបាលនៅមន្ទីរពេទ្យដែលមិនមែនជាមន្ទីរពេទ្យដៃគូររបស់ក្រុមហ៊ុន AIA តើខ្ញុំអាចទាមទារសំណងលើថ្លៃព្យាបាលបានដែរឬទេ?

បាន យើងធានាលើការព្យាបាល ទោះបីជានៅមន្ទីរពេទ្យដែលមិនមែនជាមន្ទីរពេទ្យដៃគូររបស់យើងក៏ដោយ ដរាបណាវាស្ថិតនៅក្នុងទីតាំងភូមិសាស្រ្តនៃគម្រោងវេជ្ជសាស្រ្តរបស់អ្នក។ អ្នកអាចទូទាត់ប្រាក់ត្រលប់មក

FOR INTERNAL USE ONLY

វិញលើថ្លៃព្យាបាលដែលមានលក្ខខណ្ឌគ្រប់គ្រាន់ជាមួយក្រុមហ៊ុន AIA បន្ទាប់ពីទូទាត់ថ្លៃព្យាបាលជាមួយនឹងមន្ទីរពេទ្យ។

## 49. តើក្រុមហ៊ុន AIA ប្រើពេលប៉ុន្មានថ្ងៃដើម្បីដំណើរការការទាមទារសំណង?

ក្រុមហ៊ុន សូមរក្សាសិទ្ធិក្នុងការពិចារណាលើសំណុំឯកសារ និងការសម្រេច លើការផ្តល់សំណងក្នុងរយៈពេល 15 (ដប់ប្រាំ) ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលឯកសារពេញលេញអំពីបណ្តឹងទាមទារសំណង។

## 50. តើអ្វីទៅជាការស្នើសុំការអនុញ្ញាតជាមុន?

ជានីតិវិធីដែលអ្នកត្រូវបានធានារ៉ាប់រងតម្រូវឱ្យទទួលការអនុញ្ញាតជាមុនពីក្រុមហ៊ុន មុនពេលទទួលការព្យាបាលសម្រាប់ដំណើរការសេវាវេជ្ជសាស្ត្រជាក់លាក់ណាមួយ ដូចដែលបានបញ្ជាក់នៅលើតារាងអត្ថប្រយោជន៍។

អ្នកត្រូវបានធានារ៉ាប់រង ត្រូវដាក់ទម្រង់បែបបទនៃការស្នើសុំការអនុញ្ញាតជាមុនដែលពេញលេញមកកាន់ក្រុមហ៊ុន យ៉ាងហោចណាស់ 5 ថ្ងៃធ្វើការ មុនធ្វើការណាត់ជួបទទួលដំណើរការសេវាវេជ្ជសាស្ត្រ ឬការព្យាបាលនោះ។ ក្រុមហ៊ុន នឹងត្រួតពិនិត្យ ហើយឆ្លើយតបទៅកាន់អ្នកត្រូវបានធានារ៉ាប់រងវិញ ជាលាយលក្ខណ៍អក្សរមុនការចាប់ផ្តើមនៃការព្យាបាលដែលបានស្នើសុំ។

អត្ថប្រយោជន៍ដែលអាចផ្តល់ជូនក្រោមផលិតផលធានារ៉ាប់រងបន្ថែមនេះ ត្រូវអនុលោមតាមសិទ្ធនៃការទទួលបាន ខណៈពេលដែលចំណាយនោះបានកើតឡើងជាក់ស្តែង ហើយត្រូវអនុលោមតាមខសន្យាកម្រិតអតិបរមា ការចូលរួមចំណែកនៃការចំណាយ កម្រិតមិនធ្វើសំណង និងករណីមិនធានានៃបណ្ណសន្យារ៉ាប់រងនេះ។

## 51. តើខ្ញុំអាចជូនដំណឹងទៅក្រុមហ៊ុន AIA អំពីការស្នើសុំការអនុញ្ញាតជាមុនដោយវិធីណា?

អ្នកអាចទាក់ទងទៅសេវាបម្រើអតិថិជន ទូរស័ព្ទលេខ 086 999 242 ឬទាក់ទងទៅទីប្រឹក្សាផែនការជីវិត/ ភ្នាក់ងារ/ តេឡេក្រាម។

## 52. តើនឹងមានការផាកពិន័យ ឬការបដិសេធនៃការទាមទារសំណងដែរឬទេ ប្រសិនបើអ្នកត្រូវបានធានារ៉ាប់រងមិនបានស្នើសុំការអនុញ្ញាតជាមុន?

គឺមិនមានការផាកពិន័យ ឬការបដិសេធនៃការទាមទារសំណងនោះទេ ប្រសិនបើការទាមទារសំណងនោះមានលក្ខខណ្ឌគ្រប់គ្រាន់ ប៉ុន្តែអតិថិជននឹងមិនអាចទទួលបានអត្ថប្រយោជន៍ពីការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់នៅមន្ទីរពេទ្យដៃគូរក្រៅស្រុករបស់ក្រុមហ៊ុន AIA បានទេ។

FOR INTERNAL USE ONLY

## 53. តើមន្ទីរពេទ្យណាខ្លះដែលខ្ញុំអាចប្រើប្រាស់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់សម្រាប់ការព្យាបាលបាន?

អ្នកអាចប្រើប្រាស់ការទូទាត់ដោយមិនប្រើប្រាស់សាច់ប្រាក់នៅមន្ទីរពេទ្យដៃគូរបស់យើង។ យើងកំពុងបន្តពង្រីកបណ្ដាញរបស់យើង ដើម្បីផ្ដល់នូវបទពិសោធន៍ល្អបំផុតដល់អតិថិជន។ អ្នកអាចស្វែងរកបញ្ជីមន្ទីរពេទ្យដៃគូរបស់យើងតាមរយៈ https://www.aia.com.kh/en/help-support/hospital-partners/hospital-network.html។

## 54. តើខ្ញុំអាចទាមទារសំណងលើថ្លៃព្យាបាលសម្រាប់ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងទាមទារសំណងលើអត្ថប្រយោជន៍ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ បានដែរឬទេ?

អ្នកអាចទាមទារសំណងលើថ្លៃព្យាបាលសម្រាប់ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ និងទាមទារសំណងលើអត្ថប្រយោជន៍ពិការភាពទាំងស្រុង និងជាអចិន្ត្រៃយ៍ បានប្រសិនបើអត្ថប្រយោជន៍ទាំងពីរនេះជាផ្នែកមួយនៃការធានារ៉ាប់រងរបស់អ្នក។

## 55. តើមន្ទីរពេទ្យនឹងជូនដំណឹងដល់អតិថិជនអំពីអត្ថប្រយោជន៍ដែលពួកគេត្រូវបានធានារ៉ាប់រង និងចំនួនទឹកប្រាក់ដែលពួកគេត្រូវចំណាយពីហោប៉ៅផ្ទាល់ខ្លួនបានដែរឬទេ?

បន្ទាប់ពីការព្យាបាល ប្រសិនបើវិក្កយបត្រលើសពីអត្ថប្រយោជន៍ធានារ៉ាប់រងរបស់អ្នក មន្ទីរពេទ្យនឹងជូនដំណឹងដល់អតិថិជននូវវិក័យប័ត្រថ្លៃព្យាបាលដែលលើសដែលអតិថិជនត្រូវទូទាត់ដោយខ្លួនឯង។

## 56. តើខ្ញុំអាចទូទាត់ប្រាក់ត្រលប់មកវិញបានដែរឬទេក្នុងរយៈពេលអនុគ្រោះ?

ក្រុមហ៊ុន AIA ធានារ៉ាប់រងលើថ្លៃព្យាបាលដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដែលកើតឡើងក្នុងរយៈពេលអនុគ្រោះ។

## 57. តើខ្ញុំអាចទូទាត់ប្រាក់ត្រលប់មកវិញបានដែរឬទេក្នុងកំឡុងពេលដែលបណ្ណសន្យារ៉ាប់រងអស់សុពលភាព?

ទេ ក្រុមហ៊ុន AIA នឹងមិនធានារ៉ាប់រងលើការទាមទារសំណងណាមួយដែលបានកើតឡើងបន្ទាប់ពីរយៈពេលអនុគ្រោះ និងមុនការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញនោះទេ។

## 58. តើខ្ញុំអាចតាមដានស្ថានភាពនៃការទាមទារសំណងដែលខ្ញុំបានដាក់ស្នើដោយរបៀបណា?

អតិថិជនអាចពិនិត្យមើលស្ថានភាពទាមទារសំណងតាមរយៈគេហទំព័រសម្រាប់អតិថិជន។

FOR INTERNAL USE ONLY

## X. ការបញ្ចប់បណ្ណសន្យារ៉ាប់រង

### 59. បន្ទាប់ពីបណ្ណសន្យារ៉ាប់រងត្រូវបានបញ្ចប់ តើខ្ញុំអាចទិញបណ្ណសន្យារ៉ាប់រងថ្មីបានដែរឬទេ?

បាន អ្នកអាចទិញបណ្ណសន្យារ៉ាប់រងថ្មី ប៉ុន្តែអ្នកនឹងត្រូវឆ្លងកាត់ការវាយតម្លៃហានិភ័យ។

### 60. តើខ្ញុំអាចដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញបានដែរឬទេ បន្ទាប់ពីបណ្ណសន្យារ៉ាប់រងរបស់ខ្ញុំអស់សុពលភាព?

បាន អ្នកអាចដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញក្នុងរយៈពេល 2 ឆ្នាំ គិតចាប់ពីពេលដែលអស់សុពលភាព និងស្ថិតក្នុងលក្ខខណ្ឌដូចខាងក្រោម៖

- ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរដែលធ្វើឡើងដោយម្ចាស់បណ្ណសន្យារ៉ាប់រង ដើម្បីស្នើសុំដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងនោះឡើងវិញ
- អ្នកត្រូវបានធានារ៉ាប់រងត្រូវស្ថិតក្នុងកម្រិតអាយុដែលត្រូវបានអនុញ្ញាត តាមលក្ខខណ្ឌដែលបានកំណត់ដោយក្រុមហ៊ុននៅពេលបន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ
- អ្នកត្រូវបានធានារ៉ាប់រងត្រូវផ្តល់ភស្តុតាងបញ្ជាក់ថា គាត់អាចទទួលបានអត្ថប្រយោជន៍ធានារ៉ាប់រងដែលក្រុមហ៊ុនពេញចិត្ត
- រាល់បុព្វលាភធានារ៉ាប់រងដែលហួសពេលកំណត់ នឹងត្រូវបានទូទាត់រួមនឹងការប្រាក់ក្នុងអត្រាដែលកំណត់ដោយក្រុមហ៊ុន នៅពេលស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រង
- រាល់បំណុលដែលមិនទាន់បានទូទាត់នៅពេលស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រង នឹងត្រូវបានទូទាត់ជាមួយនឹងការប្រាក់ក្នុងអត្រាដែលកំណត់ដោយក្រុមហ៊ុន និង
- បំពេញ ខ និងលក្ខខណ្ឌដទៃផ្សេងទៀតដែលក្រុមហ៊ុនអាចនឹងដាក់នៅពេលស្នើសុំបន្តសុពលភាពបណ្ណសន្យារ៉ាប់រង។

## XI. ប្រតិបត្តិការបណ្ណសន្យារ៉ាប់រង

### 61. តើត្រូវចំណាយពេលប៉ុន្មានថ្ងៃដើម្បីចេញកាតធានារ៉ាប់រង?

ត្រូវចំណាយពេល 10 ថ្ងៃនៃថ្ងៃធ្វើការ ប៉ុន្តែអតិថិជនអាចប្រើកាតនិម្មិត (virtual card) ដែលមាននៅក្នុងគេហទំព័រសម្រាប់អតិថិជន។

FOR INTERNAL USE ONLY

## 62. តើក្រុមហ៊ុននឹងផ្តល់ជូនកាតធានារ៉ាប់រងជារៀងរាល់ឆ្នាំដែរឬទេ ព្រោះផលិតផលនេះមានរយៈពេលធានារ៉ាប់រង 100 ឆ្នាំ?

ទេ ក្រុមហ៊ុននឹងមិនផ្តល់ជូនកាតធានារ៉ាប់រងជារៀងរាល់ឆ្នាំនោះទេ។ ក្រុមហ៊ុននឹងផ្តល់កាតជូនដោយឥតគិតថ្លៃសម្រាប់ការស្នើសុំលើកដំបូង។ សម្រាប់កាតដែលស្នើសុំឡើងវិញ នឹងត្រូវគិតថ្លៃ 5 ដុល្លារ ប៉ុន្តែអតិថិជនអាចប្រើកាតនិម្មិត (virtual card) ដែលមិនគិតថ្លៃ។

## 63. តើខ្ញុំអាចទទួលបានព័ត៌មានលម្អិតអំពីការធានារ៉ាប់រងរបស់ខ្ញុំដោយរបៀបណា?

អ្នកអាចស្នើសុំព័ត៌មានអំពីការធានារ៉ាប់រងរបស់អ្នកតាមរយៈគេហទំព័រសម្រាប់អតិថិជន តេឡេក្រាម AIACambodia_bot (https://t.me/AIACambodia_bot) ឬអ្នកអាចទាក់ទងទៅសេវាបម្រើអតិថិជនទូរស័ព្ទលេខ 086 999 242 ឬទាក់ទងទៅទីប្រឹក្សាផែនការជីវិត។

## 64. តើផលិតផលនេះរាប់បញ្ចូលទៅក្នុងភាពទៀងទាត់នៃការបង់បុព្វលាភ (persistency) របស់ទីប្រឹក្សាផែនការជីវិតដែរឬទេ?

ផលិតផលនេះត្រូវបានធានាបន្តសុពលភាពរហូតដល់អ្នកត្រូវបានធានារ៉ាប់រងមានអាយុ 100 ឆ្នាំ។ ដូច្នេះដូចផលិតផលធានារ៉ាប់រងផ្សេងទៀតដែលបង់ប្រាក់ធម្មតា ផលិតផលនេះរាប់បញ្ចូលទៅក្នុងភាពទៀងទាត់នៃការបង់បុព្វលាភ (persistency).

## 65. តើមនុស្សម្នាក់អាចការពារក្រោមបណ្ណសន្យារ៉ាប់រងតែមួយប៉ុណ្ណោះមែនដែរឬទេ?

មនុស្សម្នាក់អាចការពារក្រោមបណ្ណសន្យារ៉ាប់រងតែមួយប៉ុណ្ណោះ។

FOR INTERNAL USE ONLY